**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ១៩៦ សារាចរ. កសក

# សារាចរណែនាំ

# ស្តីពី

# នីតិវិធីនៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា

កន្លងមក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសង្កេតឃើញថា ការអនុវត្តអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពី "ផលិតកម្មកសិកម្មតាមកិច្ចសន្យា" បានជួបប្រទះបញ្ហាមួយចំនួនដូចជា ការមិនជឿទុកចិត្ត ការធានានូវតម្លៃ បរិមាណនិងគុណភាព ការបំពេញបែបបទឲ្យបានត្រឹមត្រូវតាមនីតិវិធី ភាពអសកម្មនៃការចូលរួមពីស្ថាប័នពាក់ព័ន្ធ កង្វះព័ត៌មានស្តីពីការស្នើសុំអនុវត្តន៍ផលិតកម្មកសិកម្មតាមកិច្ចសន្យា និងកង្វះព័ត៌មានទំនាក់ទំនងរវាងភាគីអ្នកទិញ និងភាគីអ្នកផលិត។ល។

ដើម្បីអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដូចតទៅ៖

១- ភាគីអ្នកទិញឬភាគីអ្នកផលិត ដែលមានបំណងស្វែងរកដៃគូ មានដៃគូ ឬបានចុះកិច្ចសន្យារួចហើយ ត្រូវមកផ្តល់ និងទទួលព័ត៌មាន ដើម្បីបំពេញបែបបទស្តីពីនីតិវិធីក្នុងការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យានៅនាយកដ្ឋានកសិ-ឧស្សាហកម្ម ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីខេត្តសាមី។

២- ត្រូវធ្វើការស្នើសុំការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យានៅការិយាល័យកសិ-ឧស្សាហកម្មនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្តសាមី ចំពោះភាគីដែលមានដៃគូឬបានចុះកិច្ចសន្យាលើកម្មវត្ថុនៃទឹកប្រាក់ចំនួនក្រោម ២០០,០០០,០០០៛០០(ពីររយលានរៀលគត់)។

៣- ត្រូវធ្វើការស្នើសុំការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យានៅនាយកដ្ឋានកសិ-ឧស្សាហកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំពោះភាគីដែលមានដៃគូឬបានចុះកិច្ចសន្យាលើកម្មវត្ថុនៃទឹកប្រាក់ចាប់ពី ២០០,០០០,០០០៛០០(ពីររយលានរៀលគត់) ឡើងទៅ។

៤- នាយកដ្ឋានកសិ-ឧស្សាហកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវដឹកនាំក្រុមការងារចុះពិនិត្យការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យារបស់ភាគីទាំងពីរ ដោយសហការជាមួយអង្គភាពជំនាញពាក់ព័ន្ធតាមការចាំបាច់។

៥- នាយកដ្ឋានកសិ-ឧស្សាហកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការជាមួយអង្គភាពជំនាញនិងស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តតួនាទីដូចខាងក្រោម៖

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

– តភ្ជាប់ទំនាក់ទំនងរវាងអ្នកវិនិយោគទុន និងកសិករ ផលិតករ អ្នកកែច្នៃ ក្នុងក្របខណ្ឌនៃផលិតកម្មកសិកម្មតាមកិច្ចសន្យា

– ពង្រឹង ជំរុញ និងលើកទឹកចិត្តដល់ការបង្កើតសមាគម សហគមន៍កសិកម្ម ឬអង្គការកសិករនានាដែលជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍន៍ផលិតកម្មកសិកម្មតាមកិច្ចសន្យា

– លើកកម្ពស់ស្តង់ដារ ចំណាត់ថ្នាក់ និងគុណភាពផលិតផលកសិកម្ម ឲ្យស្របតាមតម្រូវការទីផ្សារ និងនិយាមអន្តរជាតិ

– ចូលរួមសម្រុះសម្រួលក្នុងការដោះស្រាយទំនាស់ និងបញ្ហាផ្សេងៗក្នុងការអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្ម ដោយឈរលើមូលដ្ឋានច្បាប់ជាធរមាន

– បង្កភាពងាយស្រួលដល់ការធ្វើកសិធុរកិច្ច កសិ-ឧស្សាហកម្ម និងការនាំចេញ

– បង្កភាពងាយស្រួលក្នុងការទទួលបានសេវាកម្មគាំទ្របច្ចេកទេស ពូជដំណាំ ពូជវារីជាតិ ពូជរុក្ខជាតិ ពូជសត្វ មធ្យោបាយផលិតកម្មផ្សេងៗ ជីកសិកម្ម និងថ្នាំកសិកម្មប្រកបដោយគុណភាពខ្ពស់

– លើកកម្ពស់ការធ្វើប្រពលវប្បកម្ម ពិពិធកម្មកសិកម្ម និងការប្រកួតប្រជែងដើម្បីឆ្លើយតបនូវសេចក្តីត្រូវការក្នុងស្រុក និងការនាំចេញ។

៦- ការិយាល័យកសិ-ឧស្សាហកម្មនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ត្រូវធ្វើការតាមដាន វាយតម្លៃការអនុវត្តកិច្ចសន្យា និងធ្វើរបាយការណ៍មកនាយកដ្ឋានកសិ-ឧស្សាហកម្មក្នុងរយៈពេលបីខែម្តង ដើម្បីធ្វើការបូកសរុបរបាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៧- អនុញ្ញាតឲ្យនាយកដ្ឋានកសិ-ឧស្សាហកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្តប្រើប្រាស់គំរូពាក្យស្នើសុំអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា គំរូកិច្ចសន្យាផលិតកម្មកសិកម្ម និងលិខិតអនុញ្ញាតឲ្យអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាដូចមានជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ។

ទទួលបានសារាចរណែនាំនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តន៍ឲ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍អំពីលទ្ធផលនៃការអនុវត្តជូនក្រសួងវិញ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត
- នាយកដ្ឋានកសិ-ឧស្សាហកម្ម
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ